# សសរផ្អោបក្នុងស្ថាបត្យកម្មខ្មែរ

ខ្មែរ គឺជារដ្ឋមួយក្នុងចំណោមរដ្ឋទាំងបួន (ខ្មែរ ចាម មន ជ្វា) ដែលទទួលឥទ្ធិពលអារ្យធម៌ឥណ្ឌាយ៉ាងជ្រាលជ្រៅ ចាប់តាំងពីរវាងដើមគ្រិស្តសករាជមកម្ល៉េះ ពោល ទាំងផ្នែកសាសនា ភាសា អក្សរសាស្ត្រ ច្បាប់ និងទស្សនិវជ្ជា។ ទោះជាយ៉ាងណាក៏ដោយ ក្នុងវិស័យស្ថាបត្យកម្មប្រាសាទបុរាណ សិល្បករខ្មែរមិនបានចម្លងតាមគំរូស្ថាបត្យកម្មឥណ្ឌាទាំងស្រុងនោះទេ។ ស្ថាបត្យករខ្មែរនាសម័យបុរាណ បានច្នៃប្រតិដ្ឋទៅលើឥទ្ធិពលទាំងនោះជាមួយសិល្បៈផ្ទាល់ខ្លួន រហូតបង្កើតបានជាអត្តសញ្ញាណមួយរបស់ខ្លួន ដែលមានភាពខុសប្លែកពីសំណង់នៅឥណ្ឌា។ ក្នុងចំណោមគ្រឿងបង្គុំ និងគ្រឿងលម្អស្ថាបត្យកម្មដែលឆ្លុះបញ្ចាំងអំពីភាពខុសប្លែក និងភាពខ្ពង់ខ្ពស់នៃសិល្បៈខ្មែរនេះ "សសរផ្អោប" គឺជាផ្នែកមួយដែលគួរឱ្យកត់សម្គាល់។ តើសសរផ្អោបក្នុងស្ថាបត្យកម្មខ្មែរមានអត្ថន័យ តួនាទី និងលក្ខណៈសិល្បៈដូចម្ដេចខ្លះ?

សសរផ្អោប សំដៅលើសសរដែលគេឆ្លាក់ជាប់ជាមួយជញ្ជាំងប្រាសាទ ដែលដើរតួនាទីជាសមាសធាតុតុបតែងលម្អដែលមិនអាចខ្វះបាន ក្នុងការកំណត់ព្រំដែននៃផ្ទៃជញ្ជាំង សម្រាប់ជួយលើកសម្រស់ស៊ុមទ្វារ ឬជ្រុងជញ្ជាំងប្រាសាទ។ លោក Henri Marchal និងលោកស្រី Gilberte de Coral Rémusat យល់ស្របគ្នាថា សសរផ្អោប គឺជាផ្ទៃឬកន្លែងដែលសិល្បករខ្មែរអាចបង្ហាញនូវទេពកោសល្យសិល្បៈ តាមរយៈក្បាច់តុបតែងតាមបែបប្រពៃណី ជាពិសេស ក្បាច់ភ្ញីវល្លិ និងក្បាច់ពងត្រី ឱ្យស៊ីសង្វាក់គ្នាជាមួយនឹងផ្ដែរទ្វារ។ លោក Henri Marchal ក៏បានឱ្យនិយមន័យសសរផ្អោបក្នុងទំនាក់ទំនងជាមួយទ្វារបញ្ឆោតផងដែរ ដោយលោកសង្កេតឃើញថា សសរផ្អោបដើរតួនាទីជាស៊ុមខណ្ឌចែករវាងស្លាបទ្វារនីមួយៗ។ ស្រដៀងគ្នានេះដែរ លោក Henri Parmentier បានឱ្យនិយមន័យសសរផ្អោបថាជា "សសររាប" ដែលជាប់នឹងផ្ទៃជញ្ជាំង ដែលដើរតួជាអ្នកទ្រទ្រង់ផ្នែកសោភ័ណភាព និងតុល្យភាពចក្ខុ តាមរយៈការជួយបំបែកផ្ទៃជញ្ជាំងដ៏ធំសំប៉ែត ឱ្យទៅជាផ្នែកៗដែលមានរបៀបរៀបរយ ព្រមទាំងដើរតួជាបង្គោលបញ្ឈរសម្រាប់ទ្រនូវរចនាសម្ព័ន្ធផ្ដែកដូចជាផ្ដែរ និងហោជាងផងផង។ ការយល់ប្លែកពីគេមួយចំណុចនោះ លោក Henri Parmentier យល់ថាសសរផ្អោបធ្វើអំពីឥដ្ឋ ឬថ្មនៅតាមប្រាសាទនានា ជារឿយៗជាការចម្លងតាមទម្រង់សសរឈើនៃសំណង់ផ្សេងៗ ហើយលោកឱ្យតម្លៃលើសសរផ្អោបថាជា "**សាក្សីនៃស្ថាបត្យកម្មឈើ**" ដែល

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

បាត់បង់រូបរាងទៅតាមពេលវេលា។ ការសិក្សាមួយរបស់ លោក **ភឹង តារា** បានបង្ហាញថា សសរផ្តោបអាចបែងចែកជា ៣ ប្រភេទ គឺ **(១). សសរផ្តោបស៊ុមខ្លោងទ្វារ** (ទ្រទម្ងន់ហោជាងនិងផ្តែរ) **(២). សសរផ្តោបសារពើសូត្រ** (ទ្រអឌ្ឍហោជាងនិងថ្មបន្ទុបជាក្បាលនាគ) និង **(៣). សសរផ្តោបជ្រុង** (មានភាគលយជាងសសរផ្តោបសារពើសូត្រ និងមានតួនាទីដូចគ្នា)។ បន្ថែមពីនេះ ប្រសិនបើគិតទៅលើរចនាសម្ព័ន្ធ អ្នកស្រាវជ្រាវគេច្រើនបែងចែកផ្ទៃសសរផ្តោបទាំងមូលជា ៣ ផ្នែក គឺផ្នែកក្បាលសសរផ្តោប ផ្នែកតួសសរផ្តោប និងផ្នែកជើងសសរផ្តោប។

គ្រប់សសរផ្តោបទាំងបីប្រភេទខាងលើ តែងមានក្បាច់តុបតែងលម្អផ្សេងៗ តែក៏មានសសរផ្តោបប្រាសាទមួយចំនួនពុំមានក្បាច់តុបតែងលម្អដែរ។ នៅសម័យដើមដំបូងនៃស្ថាបត្យកម្មខ្មែរ (រចនាបថសំបូរព្រៃគុក) សសរផ្តោបនៅតាមប្រាសាទ ភាគច្រើនគេនិយមធ្វើសសរផ្តោបលាតទទេដោយមិនមានក្បាច់លម្អ លើកលែងតែសំណង់សំខាន់ៗ ហើយក្បាច់លម្អទាំងនោះសុទ្ធសឹងឆ្លាក់ត្រាប់តាមរុក្ខជាតិ ស្លឹកឈើ ឬផ្កាដែលមាននៅក្នុងស្រុក។ ប៉ុន្តែ ក្បាច់សសរផ្តោបនៅសំណង់គក់គ្រឹះចំនួន ៣ រួមមាន ប្រាសាទអាស្រមមហាឥសី (ប្រាង្គ N17 នៃតំបន់សំបូរព្រៃគុក) ប្រាសាទគុកព្រះធាតុ (ភ្នំហាន់ជ័យ ខេត្តកំពង់ចាម) និងប្រាសាទត្រពាំងគុក (ខេត្តព្រះវិហារ) លោក Jean Boisselier គិតថា ក្បាច់ផ្កាភ្ញីដែលឆ្លាក់ទាំងនោះ បង្ហាញយ៉ាងច្បាស់ថា ពិតជាទទួលឥទ្ធិពលសិល្បៈឥណ្ឌានៅសម័យក្រោយគុប្ត (Post-Gupta)។ ដោយឡែក ចាប់ពីរវាងចុងរចនាបថព្រៃក្មេងដើមរចនាបថកំពង់ព្រះ ការលម្អក្បាច់ភ្ញីវល្លិឆ្លាស់គ្នានៅតាមសសរផ្តោបប្រាសាទឥដ្ឋ កាន់តែវិវឌ្ឍខ្លួនគួរឱ្យកត់សម្គាល់ ដូចគេឃើញនៅប្រាសាទព្រះស្រី ប្រាសាទសក្ខ ប្រាសាទភូមិប្រាសាទ ប្រាសាទកំពង់ព្រះ ។ល។ ដែលទាំងអស់នេះ គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ឈ្ពោះបន្តទៅសម័យអង្គរ។

ដោយឡែក សសរផ្តោបនៅសម័យអង្គរវិញ លោកស្រី Gilberte de Coral Rémusat បានបែងចែកក្បាច់លម្អទាំងនោះជា ៤ ប្រភេទសំខាន់ៗ គឺ **(១). ក្បាច់តុបតែងតាមបែបប្រពៃណី** (ក្បាច់ភ្ញីវល្លិ ឬក្បាច់ពងត្រី) **(២). ក្បាច់តុបតែងញឹកញាប់** (ប្រភេទក្បាច់ទងនៃស្លឹកឈើ ឬផ្កាភ្ញី) **(៣). ក្បាច់តុបតែងម្តងម្កាល** (ក្បាច់មានរាងដូចអក្សរ S និងរាងការ៉ូ) និង **(៤) ក្បាច់តុបតែងវិសាមញ្ញ** (ក្បាច់កម្រដែលមិនសូវជួបប្រទះទូទៅ)។ ក្នុងចំណោមទាំងបួនប្រភេទនេះ លោកស្រីបញ្ជាក់ថា ក្បាច់ភ្ញីវល្លិត្រូវបានចាត់ទុកថាជាក្បាច់តុបតែងតាមបែបប្រពៃណីដែលមានប្រជាប្រិយភាពបំផុតនៅក្នុងសិល្បៈខ្មែរ។ ក្បាច់ប្រភេទនេះ ជាទម្រង់ក្បាច់ដែលមានមែកជាងរមូល ឬប្រទាក់ក្រឡាគ្នា

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ជាថ្នាក់ៗឡើងទៅលើពេញផ្ទៃតួសសរផ្តោប។ គួរកត់សម្គាល់ជាពិសេស ចាប់ពីរចនាបថព្រះគោមក គេលែងទុកឱ្យក្បាច់ភ្ញីវល្លិនៅដាច់ដោយឡែកទៀតហើយ ពោល គេបានបង្កើតឱ្យមានរូបសត្វ ឬតួអង្គសម្រាប់ "ផ្តល់កំណើត" ឬ "ទ្រ" ក្បាច់ភ្ញីទាំងនោះនៅផ្នែកខាងក្រោម (ជើងសសរ) ដែលពេលខ្លះជារូបនាគ ឬតោ ហាមាត់ខ្ជាក់ចេញក្បាច់ភ្ញីវល្លិទាំងនោះ។ មកដល់រចនាបថបន្ទាយស្រី រហូតមកដល់ចុងរចនាបថបាភួន ស្ទើរតែពេញផ្ទៃសសរផ្តោបគេនិយមឆ្លាក់មុខសត្វតោ និងមុខសត្វគ្រុឌខ្ជាក់កំពុងខ្ជាក់ក្បាច់ផ្កាភ្ញីតម្រៀបគ្នាចុះមកក្រោម។ មកដល់រចនាបថបាយ័ន្ត ជួនកាលគេឆ្លាក់រូបគ្រុឌក្នុងឥរិយាបថ "ខាំ" ឬ "ខ្ជាក់" ឬ "ចាប់" ទងនៃក្បាច់ភ្ញីវល្លិទាំងនោះ។ ស្របជាមួយក្បាច់ភ្ញីវល្លិដែលពេញនិយម ក្បាច់ពងត្រី ក៏ដើរទន្ទឹមគ្នាដែរ ដែលគេច្រើនឆ្លាក់ទៅតាមទំហំផ្ទៃនៃសសរផ្តោបនីមួយៗ ប្រសិនបើសសរផ្តោបមានផ្ទៃធំ គេអាចប្រើក្បាច់ចម្រុះ តែបើសសរផ្តោបតូចចង្អៀត គេច្រើនប្រើក្បាច់ពងត្រីដែលងាយស្រួលឆ្លាក់។

មកដល់ចុងរចនាបថបាភួន និងរចនាបថអង្គរវត្ត សសរផ្តោបដែលធ្លាប់តែពោរពេញដោយក្បាច់ផ្កាភ្ញី បានប្តូរទៅជាទីតាំងដែលសិល្បករឆ្លាក់បង្ហាញឈុតឆាករឿងទេវកថាផ្សេងៗ រូបទេពនិករ រូបអប្សរា ឬរូបទ្វារបាលជាដើម។ ការរំលេចចម្លាក់ឈុតឆាករឿងទេវកថានៅតាមសសរផ្តោប ចាប់ផ្តើមឡើងច្បាស់លាស់នៅប្រាសាទបាភួនដំបូងគេ និងក្រោយមកកាន់តែសម្បូណ៌បែបនៅក្នុងរជ្ជកាលព្រះបាទស្រីសូរ្យវរ្ម័នទី២ (រចនាបថអង្គរវត្ត) ដូចដែលឃើញមាននៅប្រាសាទអង្គរវត្ត ប្រាសាទធម្មនន្ទ ប្រាសាទចៅសាយទេវតា ប្រាសាទបន្ទាយសំរែ និងប្រាសាទបេងមាលាជាដើម។ ក្នុងចំណោមសាច់រឿងទេវកថាទាំងនោះ មានខ្លះគេមិនអាចវាយតម្លៃបានថាជារឿងអ្វីឡើយ។ រីឯសាច់រឿងទេវកថាដែលវាយតម្លៃកត់សម្គាល់បាន លោក **ភឹង តារា** បានចាត់ថ្នាក់សាច់រឿងទេវកថាទាំងនោះជា ៣ ប្រភេទ។ ប្រភេទទី១ ជាចម្លាក់**ទេវកថាព្រះឥសូរ** មានដូចជា ឈុតព្រះនាងទុគ៌ាមហិសសុរមទ៌និ សិវភិក្សាជនមូត៌ិ សិវនាដរាជ (ឥសូររាំ)។ ទី២ ជាចម្លាក់ **ទេវកថាព្រះវិស្ណុ** មានដូចជា វិស្ណុអនន្តសយន (វិស្ណុផ្ទំលើនាគ) វិស្ណុត្រីវិក្រម (វិស្ណុឈានបីជំហាន) មធុកៃដភវធ (ជ័យជម្នះព្រះវិស្ណុលើអសុរមធុនិងកៃដភ) សមុទ្រមន្ថន (កូរសមុទ្រទឹកដោះ) កលិយទមន (ក្រឹស្ណបង្ក្រាបនាគកលិយ) គោវធ៌នធរិ (ក្រឹស្ណទ្រភ្នំគោវធ៌ន) អរិស្តាសុរវធ (ក្រឹស្ណសម្លាប់បិសាចគោអរិស្ត) កុវលយាបិឌវធ (ក្រឹស្ណសម្លាប់បិសាចដំរីកុវលយាបិឌ) កេសីវធ (ក្រឹស្ណសម្លាប់សេះកេសី) កម្សវធ (ក្រឹស្ណសម្លាប់ស្តេចកម្ស) សុន្ទឧបសុន្ទវធ (យក្សសុន្ទនិងឧបសុន្ទប្រយុទ្ធគ្នា)។ ទី៣ ជាចម្លាក់ **ទេវកថារាមយណ** (រឿងរាមកេរ្តិ៍) មានដូចជា សីតាស្វយម្វរ (ឈុតព្រះរាមលើកធ្នូ) កុម្ភកន៌វធ (ឈុត

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

ព្រះរាមនិងព្រះលក្ខណ៍ប្រយុទ្ធជាមួយយក្សកុម្ភកន៌ ដែលត្រូវជាប្អូនរបស់ក្រុងរាពណ៍) សីតាហរណ (ឈុតក្រុងរាពណ៍ចាប់ពង្រត់ព្រះនាងសីតា) វាលិសុគ្រិវវធ (ស្វាពាលីនិងសុគ្រីពប្រយុទ្ធគ្នា) មារិចវធ (ការសម្លាប់យក្សមារិច ឬឈុតព្រះរាមបាញ់ប្រើសមាស) ទុណ្ឌុភិវធ (ឈុតទុណ្ឌុភិ ឬហៅថា ទូរភី ប្រយុទ្ធជាមួយស្វាពាលី)។

ជារួមមក "សសរផ្ដោប" មិនត្រឹមតែជាគ្រឿងបង្គុំស្ថាបត្យកម្មសម្រាប់ទ្រទ្រង់រចនាសម្ព័ន្ធប្រាសាទប៉ុណ្ណោះទេ ប៉ុន្តែវាគឺជាផ្ទាំងទស្សនីយភាពសិល្បៈដ៏រស់រវើក ដែលឆ្លុះបញ្ចាំងពីការវិវឌ្ឍនៃសិល្បៈខ្មែរគ្រប់សម័យកាល។ តាមរយៈការសិក្សាអំពីលក្ខណៈបច្ចេកទេស និងក្បាច់លម្អលើសសរផ្ដោប យើងអាចសង្កេតឃើញនូវភាពវៃឆ្លាតរបស់ស្ថាបត្យករខ្មែរក្នុងការបំប្លែងឥទ្ធិពលពីឥណ្ឌា ឱ្យទៅជាអត្តសញ្ញាណសិល្បៈផ្ទាល់ខ្លួនយ៉ាងវិចិត្រ។ ការប្រែប្រួលពីក្បាច់ភ្ញីវល្លិសាមញ្ញនៅសម័យមុនអង្គរ មកជាក្បាច់ចម្លាក់ដែលមានភាពស្មុគស្មាញ និងការបញ្ចូលរូបតួអង្គទេវតា ឬឈុតឆាករឿងទេវកថាក្នុងសម័យអង្គរ បានបង្ហាញឱ្យឃើញថា សសរផ្ដោបគឺជាសក្ខីភាពមិនអាចខ្វះបានក្នុងការកំណត់អាយុកាល និងរចនាបថនៃប្រាសាទបុរាណ។

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

# បញ្ជីឯកសារពិគ្រោះ

*គីង តារា, ២០០៣, ចម្លាក់សសរផ្តោប, សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យាជំនាន់ទី១០ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ។*

Bénisti, M. (2003) *Stylistics of Early Khmer Art*. New Delhi: Indira Gandhi National Centre for the Arts.

Boisselier, J. (1966) *Le Cambodge: Manuel d'archéologie d'Extrême-Orient*. Paris: Picard.

Coral Rémusat, G. (1935) *Quelques notes sur l'évolution du pilastre dans l'art d'Angkor*, RAA, Paris.

Coral Rémusat, G. (1940) *L'art khmer: Les étapes de son évolution*. Paris: Les Éditions d'Art et d'Histoire.

Marchal, H. (1951) *Le décor khmer*. Paris: Van Oest.

Stern, P. (1927) *Le temple d'Ankor Vat: L'art khmer au siècle de Suryavarman II*, Paris: G. van Oest.

Stern, P. (1938) 'Le style du Kulên (Sommet du Phnom Kulên)', *Bulletin de l'École française d'Extrême-Orient (BEFEO)*, 38(1), pp. 111-150.



រូបលេខ១៖ សសរផ្តោបប្រាសាទយាយព័ន្ធ ស.វ.ទី៧
(ប្រាង្គ S1 នៃតំបន់ប្រាសាទសំបូរព្រៃគុក)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៖ សសរផ្អោបប្រាសាទអាស្រមមហាឥសី ស.វ.ទី៧
(ប្រាង្គ N17 នៃតំបន់ប្រាសាទសំបូរព្រៃគុក)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



*រូបលេខ៣៖ សសរផ្ដោបប្រាសាទគុកព្រះធាតុ ស.វ.ទី៧ (ភ្នំហាន់ជ័យ ខេត្តកំពង់ចាម)*

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ២៤៖ សសរផ្តោបប្រាសាទគុកព្រះធាតុ ស.វ.ទី៧ (ភ្នំហាន់ជ័យ ខេត្តកំពង់ចាម)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៥៖ សសរផ្តោបប្រាសាទព្រះស្រី ចុងស.វ.ទី៧ (ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ២៦៖ សសរផ្តោបប្រាសាទកំពង់ព្រះ ស.វ.ទី៨ (ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង)



រូបលេខ៧៖ សសរផ្ដោបប្រាសាទប្រែរូប ស.វ.ទី១០ (តំបន់អង្គរ ខេត្តសៀមរាប)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៨៖ សសរផ្តោបប្រាសាទបន្ទាយស្រី ស.វ.ទី១០ (តំបន់អង្គរ ខេត្តសៀមរាប)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



*រូបលេខ៩៖ សសរផ្តោបប្រាសាទបន្ទាយស្រី ស.វ.ទី១០ (តំបន់អង្គរ ខេត្តសៀមរាប)*

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១០៖ សសរផ្តោបប្រាសាទស្នេងក្របីខាងជើង ស.វ.ទី១១ (ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១១៖ សសរផ្តោបប្រាសាទតាមាន់ធំ ស.វ.ទី១០ (ជួរភ្នំដងរែក ខេត្តឧត្តរមានជ័យ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១៤៖ សសរផ្ដោបប្រាសាទបាក្សី ស.វ.ទី១១ (តំបន់អង្គរ ខេត្តសៀមរាប)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១៣៖ សសរផ្កោបប្រាសាទអង្គរវត្ត ស.វ.ទី១២ (តំបន់អង្គរ ខេត្តសៀមរាប)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ១៤៖ សសរផ្តោបប្រាសាទអង្គរវត្ត ស.វ.ទី១២ (តំបន់អង្គរ ខេត្តសៀមរាប)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១៩៖ សសរផ្ដោបប្រាសាទអង្គរវត្ត ស.វ.ទី១២ (តំបន់អង្គរ ខេត្តសៀមរាប)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១៦៖ សសរផ្ដោបប្រាសាទបាយ័ន្ត ចុងស.វ.ទី១២ ដើមស.វ.ទី១៣(តំបន់អង្គរ ខេត្តសៀមរាប)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១៧៖ សសរផ្តោបប្រាសាទបាយ័ន្ត ចុងស.វ.ទី១២ ដើមស.វ.ទី១៣(តំបន់អង្គរ ខេត្តសៀមរាប)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១៨៖ សសរផ្តោបប្រាសាទបាយ័ន្ត ចុងស.វ.ទី១២ ដើមស.វ.ទី១៣(តំបន់អង្គរ ខេត្តសៀមរាប)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី